រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែតុលា ឆ្នាំ ១៩៩៩

# សេចក្តីសំរេចលេខ ៧១ សសរ.

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដោះស្រាយ សំរបសំរួលជាមួយប្រជាពលរដ្ឋ ដែលកាន់កាប់ដីធ្លីនៅបុរីសណ្ឋាគារ អង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៩/អនក្រ/បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៥ ស្តីអំពីបុរីសណ្ឋាគារ
- យោងតាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងអាជ្ញាធរអប្សរា

**សំរេច**

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដោះស្រាយសំរបសំរួលជាមួយប្រជាពលរដ្ឋ ដែលបានកាន់កាប់ដីធ្លីនៅបុរីសណ្ឋាគារអង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា ។

ប្រការ ២ : គណៈកម្មការអន្តរក្រសួងនេះ មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម អ៊ុន ឈុន | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- លោក ស៊ុយ សាន | តំណាងអាជ្ញាធរខេត្តសៀមរាប | អនុប្រធាន |
| ៣- ឯកឧត្តម ហេងវង្ស ប៊ុនឆាត | តំណាងក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៤- ឯកឧត្តម ឈិន គង់ហ៊ាង | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៥- ឯកឧត្តម ម៉ិន ណារិទ្ធ | តំណាងអាជ្ញាធរអប្សរា | សមាជិក |
| ៦- ឯកឧត្តម ព្រហ្ម សិទ្ធត្រា | តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- លោក យ៉ា ឡេងហាក់ | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

**ប្រការ ៣ :** គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចជាអាទិ៍ ៖

- ចុះពិនិត្យទីតាំងផ្ទៃដីចំនួន ៦០ ហិកតា ជាជំហានដំបូង ក្នុងបណ្តាផ្ទៃដីចំនួន ៥៦០ ហិកតា គ្រប់គ្រងដោយអាជ្ញាធរអប្សរា យោងតាមអនុក្រឹត្យលេខ ៧៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៥ ហើយនឹងត្រូវពង្រីកផ្ទៃដីសរុបចំនួន ១.០០៧ ហិកតា ។ កិច្ចការពិនិត្យនេះគឺដើម្បីអោយឃើញច្បាស់លាស់ថា ស្ថានភាពបច្ចុប្បន្នគ្មានអ្វីប្រែប្រួល ធៀបទៅនឹងស្ថានភាពដែលកត់ត្រាក្នុងរបាយការណ៍របស់អាជ្ញាធរអប្សរាឆ្នាំ ១៩៩៥ ។
- ធ្វើការវាយតំលៃ និងកំណត់ថ្លៃដីសមស្របសំរាប់ធ្វើការដោះស្រាយតាមបែបការផ្តល់ប្រាក់កាត់ ជូនប្រជាពលរដ្ឋដែលមានការពាក់ព័ន្ធ គឺថា ប្រជាពលរដ្ឋមានប័ណ្ណសំគាល់សិទ្ធិ កាន់កាប់ដីធ្លី ត្រូវដោះស្រាយតាមបែបការកិតលោ ប្រជាពលរដ្ឋដែលមានតែបង្កាន់ដៃត្រូវដោះស្រាយ ការកិតលោ ហើយអ្នកឥតមានឯកសារសំអាងត្រូវដោះស្រាយការកិតលោ អ្នកមានផ្ទះសំណង់នៅលើដីនោះ ហើយរស់នៅជាប្រចាំ និងបានធ្វើអាជីវកម្មលើដីនោះ ត្រូវដោះស្រាយការកិតលោ ។ល។
- ត្រូវរាយការណ៍ពីលទ្ធផលជូនក្រុមប្រឹក្សាភិបាល អាជ្ញាធរអប្សរាដើម្បីពិនិត្យ និងសំរេច ។

**ប្រការ ៤ :** គណៈកម្មការអន្តរក្រសួងនេះ ត្រូវសហការជាមួយគណៈកម្មការចំពុះសំរាប់ដោះស្រាយ ការតវ៉ា ទំនាស់ដីធ្លីខេត្តសៀមរាប ដែលបានបង្កើតដោយដីកាអភិបាលខេត្តសៀមរាបលេខ ១៣៧ សសរ. ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៩៩ ។

**ប្រការ ៥ :** ថវិកាសំរាប់យកមកសំរបសំរួល ប៉ះប៉ូវ ជូនប្រជាពលរដ្ឋដែលត្រូវចាកចេញពីបរិវេណសណ្ឋាគារ ព្រមទាំងសោហ៊ុយធ្វើដំណើរ និងស្នាក់នៅខេត្តសៀមរាប ជាបន្ទុករបស់អាជ្ញាធរអប្សរា ។

**ប្រការ ៦ :** ទីស្តីការគណៈរដ្ឋមន្ត្រី អាជ្ញាធរអប្សរា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រុមប្រឹក្សាអ្នកច្បាប់ ខេត្តសៀមរាប គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ២ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***